ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៦១
ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩
សាលដីកា
លេខ ៣៨ IV
ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជាសាធារណៈ ពិភាក្សាដេញដោល ស្តាប់សេចក្តីសន្និដ្ឋានភាគីពាក់ព័ន្ធ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធាន
២.លោក [redacted] ជាចៅក្រម
៣.លោក [redacted] ជាចៅក្រម
៤.លោក [redacted] ជាចៅក្រម
៥.លោកស្រី [redacted] ជាចៅក្រម

## ចៅក្រមរបាយការណ៍
-លោកស្រី [redacted]

## ក្រឡាបញ្ជីសវនាការ
-កញ្ញា [redacted]

## តំណាងមហាអយ្យការ
-លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣១៤ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ [redacted] គន្ធា និងជនត្រូវចោទឈ្មោះ [redacted] ម៉ាឡែន ចំពោះសាលដីកាលេខ ០២ "ក្រIIIសណ" ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

បុគ្គលប្តឹងសាទុក្ខ ៖

១.ជនត្រូវចោទឈ្មោះ [redacted] គន្ធា ភេទប្រុស ឆ្នាំកំណើត១៩៧២ សញ្ជាតិខ្មែរ មានមុខរបរពាណិជ្ជកម្ម មានទីកន្លែងកំណើតនៅភូមិកំពង់ចម្លង ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣ នាក់ ។ ជានីតិជន ។ ទោសពីមុនគ្មាន។

មានមេធាវី [redacted] ស៊ីថន និង [redacted] លីហៀង ជាអ្នកការពារ។



Scanned with CamScanner

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទបរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ និងពីបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១៧ រហូតដល់ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២.ជនត្រូវចោទឈ្មោះ [redacted] ម៉ាឡែន ភេទស្រី ឆ្នាំកំណើត ១៩៧៤ សញ្ជាតិខ្មែរ មុខរបរជាប្រធានគណនេយ្យ ទីកន្លែងកំណើតនៅភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ស្ត្រីមេម៉ាយ ។ មានកូនចំនួន ០២ នាក់។ ជានីតិជន ។ ទោសពីមុនគ្មាន។

មានមេធាវី [redacted] ស៊ីថន និង [redacted] លីហៀង ជាអ្នកការពារ។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទគំរាមកំហែងហែកកេរ្តិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧២ និងមាត្រា ៣៧៣ នៃក្រមព្រហ្មទណ្ឌ និងពីបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីមាន ៖

១.ឈ្មោះ [redacted] មុំ ភេទស្រី អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ។

២.ឈ្មោះ [redacted] សុខលីន ភេទប្រុស អាយុ ២៥ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តត្បូងឃ្មុំ។

៣.ឈ្មោះ [redacted] ចន្ទ្រា ភេទប្រុស អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] រាជធានីភ្នំពេញ។

៤.ឈ្មោះ [redacted] ធីរ៍ ភេទប្រុស អាយុ ៣៧ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តតាកែវ។

មានលោកស្រីមេធាវី [redacted] រ័ត្នមុន្នី ជាអ្នកការពារ។



Scanned with CamScanner

អំពីអង្គហេតុ

កាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៧ ឈ្មោះ [redacted] គន្ធា បានចុះកិច្ចសន្យាជាភ្នាក់ងារលក់អចលនទ្រព្យទទួលកម្រៃជើងសាជាមួយឈ្មោះ [redacted] មុំ ភេទស្រី អាយុ ៣៥ ឆ្នាំ និងឈ្មោះ [redacted] សុខលីន ភេទប្រុស អាយុ ២៨ ឆ្នាំ ដែលជាអ្នកទទួលគម្រោងលក់ផ្ទះល្វែងឱ្យក្រុមហ៊ុន VIP ។ ពេលនោះឈ្មោះ [redacted] គន្ធា បានចុះកិច្ចសន្យាខាងលើរួច គាត់ក៏បានឱ្យឈ្មោះ [redacted] ធីរ៍ ភេទប្រុស អាយុ ៣៧ ឆ្នាំ ដែលមានតួនាទីជាប្រធានក្រុមទីផ្សាររបស់ក្រុមហ៊ុនប្រូវីក (provic) ធ្វើការរកអតិថិជនដើម្បីទិញផ្ទះល្វែងខាងលើ។ ក្រោយមកឈ្មោះ [redacted] ធីរ៍ បានរកអតិថិជនបានចំនួន ១០២ នាក់ ទៅទិញផ្ទះរបស់បុរី VIP ចំនួន ១០២ ល្វែង សរុបទឹកប្រាក់កម្រៃជើងសាដែលឈ្មោះ [redacted] ធីរ៍ ទទួលបានសរុបចំនួន ១២.៨៥០ ដុល្លារ ពីឈ្មោះ [redacted] គន្ធា និងឈ្មោះ [redacted] ម៉ាឡែន ដែលជាប្រធានគណនេយ្យ ។ តែឈ្មោះ [redacted] គន្ធា បានទូទាត់ប្រាក់ឱ្យបានត្រឹមតែចំនួន ៥.៥៥០ ដុល្លារ តែប៉ុណ្ណោះ។ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ ឈ្មោះ [redacted] មុំ បានចេញមូលប្បទានប័ត្រមួយសន្លឹករបស់ធនាគារភ្នំពេញពាណិជ្ជលេខ ១២០០១១៤៦៩៤៨០ ឱ្យទៅឈ្មោះ [redacted] គន្ធា ដែលមានចុះទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ ដោយ កំណត់ឱ្យបើកនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ។ តែឈ្មោះ [redacted] គន្ធា និងឈ្មោះ [redacted] ម៉ាឡែន មិនបានយកប្រាក់ទៅបើកឱ្យទៅឈ្មោះ [redacted] ធីរ៍ នោះទេ។ ស្រាប់តែនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ឈ្មោះ [redacted] ម៉ាឡែន បានប្រើគណនីហ្វេសប៊ុករបស់ឈ្មោះ Lovely Khmer សរសេរបង្ហោះក្នុងបណ្តាញទំនាក់ទំនងសង្គម(Facebook)ថា "កុំព្យាយាមធ្វើបាប Provic អី បើខ្ញុំទ្រាំលែងបាន អ្នកប្រាកដជាខ្មាសគេដោយសារទង្វើអាក្រក់របស់អ្នកកន្លងមក"។ ដើម្បីធ្វើឱ្យក្រុមហ៊ុនបុរី VIP ខូចកិត្តិយស។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ឈ្មោះ [redacted] គន្ធា បានប្រើគណនីហ្វេកប៊ុករបស់ខ្លួនឈ្មោះ Kunthea Srun សរសេរបង្ហោះក្នុងបណ្តាញទំនាក់ទំនងសង្គម(Facebook)ថា "តើម្ចាស់បុរី VIP ពិតជាគ្មានលុយបើកឱ្យអ្នកទីផ្សារមែនឬ? " និង "តើប៉ុន្មានខែទើបម្ចាស់បុរី VIP បើកលុយកម្រៃជើងសាឱ្យអ្នកទីផ្សារម្តង? ហើយប៉ុន្មានភាគរយនៃលុយដែលត្រូវបើក និងត្រូវរំលែកជាប៉ុន្មានដងម្តងត្រូវរង់ចាំរយៈពេលប៉ុន្មានថ្ងៃ? សូមបញ្ជាក់ឱ្យច្បាស់លាស់!" ហើយឈ្មោះ [redacted] បូរី ក៏បានធ្វើការចែករំលែក (Share) បន្តក្នុងបណ្តាញទំនាក់ទំនងសង្គម(Facebook) ទាំងដែលក្រុមហ៊ុនបុរី VIP បានធ្វើការទូទាត់ប្រាក់ឱ្យក្រុមហ៊ុន Provic រួចរាល់អស់ហើយ។

Scanned with CamScanner

-បានឃើញដីកាសម្រេចមិនឃុំខ្លួនជាបណ្ដោះអាសន្នលេខ ៦៧៤០ (ឆ.១) ដ.ព.ស ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១.មិនឃុំខ្លួនឈ្មោះ [redacted] គន្ធា ភេទប្រុស អាយុ ៤៧ ឆ្នាំ ជនជាតិខ្មែរ មានមុខរបរអ្នករកស៊ី ទីកន្លែងកំណើតនៅភូមិកំពង់ចម្លង ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល មានទីលំនៅ [redacted] ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣ នាក់ ។ ជានីតិជន ។ ទោសពីមុនគ្មាន។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទបរិហារកេរ្ដិ៍ជាសាធារណៈ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ និងបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩។ បទល្មើសព្រហ្មទណ្ឌមានចែងនឹងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៥, មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២.ដីកាសម្រេចនេះមានសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញដីកាសម្រេចមិនឃុំខ្លួនជាបណ្ដោះអាសន្នលេខ ៦៧៤២ (ឆ.១) ដ.ព.ស ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១.មិនឃុំខ្លួនឈ្មោះ [redacted] ម៉ាឡែន ភេទស្រី អាយុ ៤៥ ឆ្នាំ ជនជាតិខ្មែរ មុខរបរប្រធានគណនេយ្យ ទីកន្លែងកំណើតភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្ដីឈ្មោះ [redacted] (លែងលះ) មានកូនចំនួន ០២ នាក់ ។ ជានីតិជន ។ទោសពីមុនគ្មាន។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទគំរាមកំហែងហែកកេរ្ដិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ និងបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩។ បទល្មើសព្រហ្មទណ្ឌមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧២, មាត្រា ៣៧៣, មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២.ដីកាសម្រេចនេះមានសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។



Scanned with CamScanner

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៩៧ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុំ, ឈ្មោះ [redacted] សុខលីន, ឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ធីរ៍ ប្តឹងមិនសុខចិត្តទៅនឹងដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្នលេខ ៦៧៤០ (ឆ.១) ដ.ព.ស, ៦៧៤២ (ឆ.១) ដ.ព.ស ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១០០ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់លោក [redacted] ម៉ាកនី ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ប្តឹងមិនសុខចិត្តទៅនឹងដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្នលេខ ៦៧៤០ (ឆ.១) ដ.ព.ស និងលេខ ៦៧៤២ (ឆ.១) ដ.ព.ស ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ០២ "ក្រឡាសណា" ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ប្រកាសថា បណ្តឹងឧទ្ធរណ៍លេខ ៩៧ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ, ឈ្មោះ [redacted] មុំ, ឈ្មោះ [redacted] សុខលីន និងឈ្មោះ [redacted] ធីរ៍ មិនអាចទទួលយកបាន។

២.ទទួលបណ្តឹងឧទ្ធរណ៍លេខ ១០០ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

៣.បដិសេធចោលដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ ៦៧៤០ (ឆ១) ដពស និងលេខ ៧៦៤២ (ឆ១) ដពស ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

៤.សម្រេចចាប់ខ្លួន និងឃុំខ្លួនលើជនត្រូវចោទ៖

ក.ឈ្មោះ [redacted] គន្ធា ភេទប្រុស អាយុ ៤៧ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិកំពង់ចម្លង ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទបរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា

Scanned with CamScanner

៣០៥ នៃក្រមព្រហ្មទណ្ឌ និងពីបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

ខ.ឈ្មោះ [redacted] ម៉ាឡែន ភេទស្រី អាយុ ៤៥ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ។

ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទគំរាមកំហែងហែកកេរ្តិ៍ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧២ និងមាត្រា ៣៧៣ នៃក្រមព្រហ្មទណ្ឌ និងពីបទរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៥.ចេញដីកាចាប់ខ្លួនជនត្រូវចោទទាំងពីរមកឃុំខ្លួននៅមន្ទីរឃុំឃាំងនៃក្រសួងមហាផ្ទៃ។

៦.សាលដីកានេះ ជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩។

-បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ ៣១៤ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់ជនត្រូវចោទឈ្មោះ [redacted] គន្ធា និងជនត្រូវចោទឈ្មោះ [redacted] ម៉ាឡែន ប្តឹងសាទុក្ខមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ០២ "កប.សេណ" ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## នាពេលសវនាការ

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា ជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាព យោងតាមមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ នៅក្នុងសំណុំរឿងនេះគឺ បទល្មើសជាបទមជ្ឈិម ហើយពាក់ព័ន្ធទៅនឹងកម្រៃជើងសាដែលធ្វើការរកអតិថិជនដើម្បីទិញផ្ទះល្វែង ដែលជាកិច្ចសន្យាមួយរវាងភ្នាក់ងារលក់អចលនវត្ថុជាមួយនឹងអ្នករកអតិថិជន ដើម្បីបានកម្រៃជើងសាតែប៉ុណ្ណោះ។ ដូចនេះយោងតាមអង្គហេតុនេះ គឺមិនមានមូលហេតុចាំបាច់នៃការឃុំខ្លួនជនត្រូវចោទតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះឡើយ។ ម្យ៉ាងជនត្រូវចោទមានអាសយដ្ឋានច្បាស់លាស់ ហើយបានតម្កល់ប្រាក់ធានាដែលមានបង្កាន់ដៃទទួលប្រាក់លេខ ៣២ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩



Scanned with CamScanner

របស់សាលាដំបូងក្រុងភ្នំពេញស្របតាមមាត្រា ២២៣ ចំណុចទី៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ការសម្រេចមិនឃុំខ្លួនរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ គឺមានលក្ខណៈត្រឹមត្រូវហើយ។

តំណាងមហាអយ្យការស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

១.ទទួលបណ្តឹងសាទុក្ខលេខ ៣១៤ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] គន្ធា និងឈ្មោះ [redacted] ម៉ាឡែន ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

២.គប្បីក្រុមប្រឹក្សាពិចារណា សម្រេចតាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដាក់ក្រោមការពិនិត្យតាមផ្លូវតុលាការ។

-លោកស្រីមេធាវី [redacted] ស៊ីថន ជាអ្នកការពារឱ្យជនត្រូវចោទឈ្មោះ [redacted] គន្ធា និង [redacted] ម៉ាឡែន បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនគឺជាអ្នកទទួលកម្រៃជើងសាពីឈ្មោះ [redacted] មុំ និង [redacted] សុខលីន ដែលជាអ្នកតំណាងឱ្យក្រុមហ៊ុនបុរី VIP ហើយការទូទាត់កម្រៃជើងសានេះ គឺត្រូវបង់ជាតំណាក់កាលនៃការលក់ទិញ។ ក៏ប៉ុន្តែកូនក្តីរបស់ខ្លួនមិនមែនលក់ដោយខ្លួនឯងនោះទេ គឺមានភ្នាក់ងារឈ្មោះ [redacted] ធីរ៍ ជាអ្នកតំណាងលក់ឱ្យ ដោយគិតភាគរយពីកូនក្តីខ្លួន ហើយកូនក្តីខ្លួនក៏ទទួលប្រាក់កម្រៃជើងសាពីឈ្មោះ [redacted] មុំ និង [redacted] សុខលីន ។ នៅចុងឆ្នាំ២០១៨ និងដើមឆ្នាំ២០១៩ ឈ្មោះ [redacted] មុំ និង [redacted] សុខលីន ចាប់ផ្តើមធ្វើការលក់ខ្លួនឯង ទើបធ្វើឱ្យមានការពិបាកក្នុងការទូទាត់ជាមួយកូនក្តីខ្លួន ហើយកូនក្តីខ្លួនក៏ពិបាកក្នុងការទូទាត់ជាមួយបុគ្គលិកផ្សេងទៀតដែរ។ កូនក្តីខ្លួនបានសួរអំពីរឿងបើកប្រាក់កម្រៃជើងសានេះ ។ ប៉ុន្តែឈ្មោះ [redacted] មុំ និង [redacted] សុខលីន នៅតែបើកប្រាក់ឱ្យកូនក្តីខ្លួនមានភាពលំបាកជាងដែល១ ដូច្នេះហើយទើបកូនក្តីរបស់ខ្លួនសុំជួបម្ចាស់បុរី VIP ផ្ទាល់តែម្តង ។ តែពិបាកនឹងសុំជួបណាស់ ពីព្រោះតែក្រុមហ៊ុននេះមានអ្នកតំណាងផ្តាច់មុខគឺឈ្មោះ [redacted] មុំ និង [redacted] សុខលីន ហេតុនេះហើយទើបវាកើតជាមានរឿងផុសក្នុងបណ្តាញទំនាក់ទំនងសង្គម (Facebook) ។ តែការផុសរបស់កូនក្តីខ្លួន គឺមិនមានបំណងក្នុងការគំរាមកំហែងអ្វីនោះទេ គឺគ្រាន់តែសួរថា តើម្ចាស់បុរី VIP ពិតជាគ្មានប្រាក់បើកឱ្យបុគ្គលិកពិតមែនទេ? ហេតុអ្វីក៏ពិបាកខ្លាំងម្លេះ? បានជាកូនក្តីខ្លួនពិបាកក្នុងការទទួលបាន ប្រាក់កម្រៃជើងសានេះ? ការផុសនេះពុំមានបំណងអាក្រក់នោះទេ គឺជាការចោទជាសំនួរ។ ចំណែកឯ ឈ្មោះ [redacted] ធីរ៍ ពីដើមឡើយជាភ្នាក់ងារកម្រៃជើងសារបស់កូនក្តីខ្លួនទេតែភាគីឈ្មោះ [redacted] មុំ និងឈ្មោះ [redacted] សុខលីន បានប្រាប់គាត់ថា បានបើកប្រាក់ឱ្យកូនក្តីខ្លួនរួចអស់ហើយ តែមិនដឹងមូលហេតុអ្វីបានជាកូនក្តីខ្លួនមិនព្រមបើកឱ្យឈ្មោះ [redacted] ធីរ៍ នោះទេ ។ ដូចនេះ ធ្វើឱ្យឈ្មោះ [redacted] ធីរ៍ ធ្វើការប្តឹងកូនក្តីខ្លួនតែម្តង ដោយមិនបានសួរនាំអ្វីមួយម៉ាត់ទេ។ ចំណែកមូលហេតុដែលកូនក្តីរបស់ខ្លួនប្តឹងសាទុក្ខនេះ គឺដោយសារតែសាលាឧទ្ធរណ៍សម្រេចសេចក្តីមានលក្ខណៈផ្ទុយនឹងច្បាប់។ សាលាឧទ្ធរណ៍មិនបានធ្វើការជូនដំណឹងទៅដល់កូនក្តីខ្លួនឱ្យចូលរួមសវនាការនោះទេ ទោះបីជាខ្លួនបានទទួលការជូនដំណឹងនោះហើយក៏ដោយ តែខ្លួនមិនមានតួនាទីអ្វីក្នុងការជូនដំណឹងទៅកូនក្តីទេ



Scanned with CamScanner

ព្រោះតាមច្បាប់អ្នកដែលមានសិទ្ធិជូនដំណឹងគឺអយ្យការ ឬ សភាស៊ើបសួរ ។ តែជាក់ស្តែងពុំមានការជូនដំណឹងដល់កូនក្តីខ្លួនឡើយ តែបែរជាមកចោទកូនក្តីខ្លួនថា មិនគោរពតាមច្បាប់ទៅវិញ។ រីឯសកម្មភាពប្រព្រឹត្តរបស់កូនក្តីខ្លួន គឺពុំមែនជាបទល្មើសទេ ព្រោះវាគ្មានធាតុផ្សំគ្រប់គ្រាន់ទៅតាមបទគំរាមកំហែងហែកកេរ្តិ៍ ព្រោះថា អង្គហេតុពុំមានការគំរាម, ចំពោះបទរំលោភលើទំនុកចិត្តវិញ តាំងពីដើមមកកូនក្តីខ្លួនមិនដែលបដិសេធក្នុងការបើកប្រាក់ឱ្យឈ្មោះ [redacted] ធីរ៍ ទេ គឺទូទាត់ឱ្យរហូត ។ តែឈ្មោះ [redacted] ធីរ៍នៅតែប្តឹងកូនក្តីខ្លួនទៀត ពុំព្រមសួរនាំរកហេតុផលទេ។ គោលការណ៍នៃការធានាសេរីភាពរបស់គ្រប់ជនទាំងអស់ត្រូវបានធានា លើកលែងតែមានករណីផ្សេងដូចជា ដើម្បីការពារសាក្សីពីការគំរាមរបស់ជនជាប់ចោទ ឬដើម្បីកុំឱ្យជនជាប់ចោទគេចវេសពីនីតិវិធីតុលាការជាដើមនោះ ខ្លួនសុំបញ្ជាក់ថា ភាគីដើមបណ្តឹងបានរក្សាទុកនូវភស្តុតាងរួចអស់ហើយ ចឹងតើកូនក្តីខ្លួនទៅបំផ្លាញភស្តុតាងដោយវិធីណា? ចំពោះសាក្សីវិញអ្នកដែលទទួលដឹងលឺគឺមានរាប់ពាន់អ្នកដែលជា Friends នៅក្នុងបណ្តាញទំនាក់ទំនងសង្គម (Facebook) របស់កូនក្តីខ្លួន ដូចនេះ នៅពេលដែលកូនក្តីខ្លួនផុសនោះមាន Friends រាប់ពាន់នាក់បានឃើញ បានដឹង បានលឺ ចឹងតើយើងត្រូវការពារសាក្សីទាំងនោះ ឬក៏យ៉ាងណា? ចំពោះការគេចវេះ កូនក្តីខ្លួនមិនដែលគេសវេះពីនីតិវិធីតុលាការម្តងណាទេ ពីព្រោះកូនក្តីខ្លួនមានអាសយដ្ឋានច្បាស់លាស់និងជាប្រធានក្រុមហ៊ុន មានបុគ្គលិកជាច្រើនដែលត្រូវទទួលខុសត្រូវ។ ដូច្នេះខ្លួនសុំសន្និដ្ឋានថា សាលាឧទ្ធរណ៍សម្រេចពុំត្រឹមត្រូវនោះទេ ខ្លួនសំណូមពរសុំឱ្យតុលាការកំពូលមេត្តាលុបចោលសាលដីការបស់សាលាឧទ្ធរណ៍ និងតម្កល់ដីកាសម្រេចរបស់សាលាដំបូងទុកជាបានការ។

-លោក [redacted] លីហៀង ជាមេធាវីការពារឱ្យជនត្រូវចោទឈ្មោះ [redacted] គន្ធា និងឈ្មោះ [redacted] ម៉ាឡែន បានធ្វើសេចក្តីសន្និដ្ឋានថា ចំពោះប្រាក់តម្កល់ កូនក្តីរបស់ខ្លួនបានយកប្រាក់ទៅតម្កល់រួចហើយ តែមានមួយសន្លឹកមានបញ្ហាទើបកូនក្តីខ្លួនស្នើសុំដាក់ធានាពេលក្រោយវិញ តែពួកខ្លួនបានចេញប្រាក់ធានាជំនួសរួចហើយ។

-លោកស្រី [redacted] វឌ្ឍមុន្នី ជាមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា ឈ្មោះ [redacted] ធីរ៍ ជាអ្នកណែនាំឱ្យកូនក្តីខ្លួនស្គាល់ភាគីជនត្រូវចោទទាំងពីរ ដើម្បីជនត្រូវចោទរកស៊ីទទួលកម្រៃជើងសាជាមួយគ្នា ហើយក៏បានចុះកិច្ចសន្យាការងារជាមួយគ្នាថែមទៀត។ កិច្ចសន្យាការងារមានរយៈពេល ២ ឆ្នាំហើយ នៅឆ្នាំ២០១៩ ក៏បានបញ្ចប់ ដោយសារតែភាគីជនត្រូវចោទមិនគោរពតាមកិច្ចសន្យា ដូចនេះទើបកូនក្តីខ្លួនបានបញ្ឈប់កិច្ចសន្យានោះ។ តែកូនក្តីខ្លួនបានបើកប្រាក់ឱ្យទៅភាគីជនត្រូវចោទតាមរយៈសែក [មូលប្បទានប័ត្រ] ដោយឈ្មោះ [redacted] គន្ធា ជាអ្នកទៅបើក ហើយអ្នកដែលចុះហត្ថលេខាទទួលគឺឈ្មោះ [redacted] ម៉ាឡែន តែមិនដឹងថា មូលហេតុអ្វីនោះទេ ទើបបានជាភាគីជនត្រូវចោទផុសគំរាមនៅក្នុងបណ្តាញទំនាក់ទំនងសង្គម(Facebook)ថា កូនក្តីខ្លួនមិនបានបើកប្រាក់កម្រៃជើងសាឱ្យទៅវិញ ដែលវាធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់បុរី VIP ហើយតែងតែទម្លាក់កំហុសទៅលើម្ចាស់បុរី

Scanned with CamScanner

VIP ថាមិនព្រមបើកប្រាក់ឱ្យ។ ភាគីជនត្រូវចោទនៅតែទៅបើកប្រាក់ពីម្ចាស់បុរី VIP កាលដែលជនត្រូវចោទឆ្លើយថា មិនដែលស្គាល់ម្ចាស់បុរី នោះគឺពុំត្រឹមត្រូវទេ។ ជនត្រូវចោទនៅតែផុសជៀមដាមជេរប្រមាថ ទៅលើម្ចាស់បុរីជាបន្តបន្ទាប់ តែជនត្រូវចោទមិនដែលទទួលស្គាល់កំហុសរបស់ខ្លួនម្តងណាឡើយ។ សាលាឧទ្ធរណ៍បានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ ពីព្រោះជនត្រូវចោទបានប្រព្រឹត្តបទល្មើសបីប្រភេទរួមគ្នា គឺបទគំរាមកំហែងហែកកេរ្តិ៍ បទបរិហារកេរ្តិ៍ជាសាធារណៈ និងបទរំលោភលើទំនុកចិត្ត។ ដូច្នេះ ការឃុំខ្លួននេះ គឺត្រឹមត្រូវហើយ ចំពោះការលើកឡើងរបស់សហភាគាថា គាត់មិនមានសិទ្ធិជូនដំណឹងទៅកូនក្តីរបស់គាត់ទេ ចឹងសួរថាប្រសិនបើខ្លួនមិនបានជួបកូនក្តីរបស់ខ្លួនចឹងតើស្នាមមេដៃនោះបានមកពីណា? ហើយនីតិវិធីតាំងពីក្រោមមកដល់តុលាការកំពូលនេះ គាត់នៅលើកឡើងដដែលៗ អំពីការមិនជូនដំណឹង តែជាក់ស្តែងគាត់ដឹងលឺអំពីការជូនដំណឹងនេះរួចហើយ តែគាត់បដិសេធមិនព្រមទទួល នេះជាការគេសវេះមិនទទួលខុសត្រូវរបស់ជនត្រូវចោទ។ ចំពោះប្រាក់តម្កល់ដែលមានបញ្ហា គឺភាគីជនត្រូវចោទមានបំណងពន្យារពេលក្នុងនីតិវិធីតុលាការ។ ហើយការចូលខ្លួនរបស់ជនត្រូវចោទ គឺមិនបានចូលរួមសវនាការតាំងពីសាលាដំបូងរហូតមក។ ខ្លួនសំណូមពរ សុំតម្កល់សាល-ដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-លោកស្រី [redacted] ស៊ីថន បានធ្វើសេចក្តីសន្និដ្ឋានបន្ថែមថា ប្រាក់តម្កល់ដែលមានបញ្ហានោះនៅពេលដែលខាងធនាគារជាតិជូនដំណឹងថា មានមួយសន្លឹកមានបញ្ហានោះ ខ្លួនបានយកទៅដូរភ្លាមតែម្តងពុំបានពន្យារនោះទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីមេធាវីការពារជនត្រូវចោទនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣១៤ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] គន្ធា និងឈ្មោះ [redacted] ម៉ាឡែន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ , មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

២.យល់ឃើញថា ការដែលសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញសំអាងហេតុថា "ជនត្រូវចោទមិនបានអនុវត្តតាមការត្រួតពិនិត្យរបស់តុលាការ ការសម្រេចមិនឃុំខ្លួនជនត្រូវចោទអាចធ្វើឱ្យប៉ះពាល់ដល់នីតិវិធីនៃការស៊ើបសួរ អាចមានការគាបសង្កត់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី និងតម្រុយជាភស្តុតាង និងដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី" នោះជាការមិនត្រឹមត្រូវនោះទេ ដោយហេតុថា៖

-សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ មិនបានផ្ដល់សំអាងហេតុពន្យល់ពីសកម្មភាពជាក់លាក់ណាមួយរបស់ជនត្រូវចោទដែលមិនអនុវត្តតាមកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ដូចមានចែងក្នុងដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៤១ (ធ.១) ដ.ព.ស និងលេខ ៦៧៤៣ (ធ.១) ដ.ព.ស ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩។

-សភាស៊ើបសួរនៃសាលាឧទ្ធរណ៍មិនបានផ្ដល់សំអាងហេតុជាក់លាក់ពន្យល់ពីលទ្ធភាពនៃការគាបសង្កត់ដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី ការធ្វើឱ្យប៉ះពាល់ដល់តម្រុយជាភស្តុតាង និងមិនបានបញ្ជាក់ពីភាពចំបាច់ណាមួយដែលត្រូវរក្សាទុកជនត្រូវចោទក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ន ដើម្បីទុកជូនតុលាការចាត់ការតាមនីតិវិធីឡើយ ។

៣.យល់ឃើញថា ជនត្រូវចោទឈ្មោះ [redacted] គន្ធា ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទបរិហារកេរ្តិ៍ជាសាធារណៈ និងបទរំលោភលើទំនុកចិត្ត ដែលជាបទលហុ និងបទមជ្ឈិម ហើយជនត្រូវចោទឈ្មោះ [redacted] ម៉ាឡែន ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទគំរាមកំហែងហែកកេរ្តិ៍ និងបទរំលោភលើទំនុកចិត្ត ដែលជាបទមជ្ឈិម។ ជនត្រូវចោទឈ្មោះ [redacted] គន្ធា ក៏បានដាក់ប្រាក់ធានាចំនួន ៧.០០០ ដុល្លារអាមេរិក រួចហើយដែរ។ ហេតុដូច្នេះ ពុំមានភាពចាំបាច់អ្វីក្នុងការឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន ស្របតាមបទប្បញ្ញត្តិមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះឡើយ។

៤.យល់ឃើញថា បណ្ដឹងសាទុក្ខរបស់ជនត្រូវចោទមានមូលហេតុនៃបណ្ដឹងសាទុក្ខត្រឹមត្រូវសមស្របតាមបទប្បញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ០២ "ក្រIIIសេណ" ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្ដីមកនេះមិនត្រឹមត្រូវតាមច្បាប់ទេ។

៦.យល់ឃើញថា ការបដិសេធសាលដីកាព្រហ្មទណ្ឌរបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ដូចក្នុងសំអាងហេតុខាងលើនេះ វាមានអានុភាពឱ្យតុលាការកំពូលពិចារណាសម្រេចរំលត់អានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួនលេខ ១៤៩ ដ.ក.ខ/១៩ និងលេខ ១៥០ ដ.ក.ខ/១៩ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ។



Scanned with CamScanner

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១.ទទួលបណ្តឹងសាទុក្ខលេខ ៣១៤ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] គន្ធា និងឈ្មោះ [redacted] ម៉ាឡែន ។

២.បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ០២ “ក្រ.ប.ស.ណ” ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ។

៣.រំលត់អានុភាពដីកាបង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួនលេខ១៤៩ ដ.ក.ឧ/១៩ និងលេខ ១៥០ ដ.ក.ឧ/១៩ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។

Scanned with CamScanner